# ព្រះពុទ្ធ ២៨ ព្រះអង្គ

# វេមត្តកថា

## អាយុវេមត្ត , បមាណវេមត្ត , កុលវេមត្ត
## បធានវេមត្ត , រស្មីវេមត្ត , យានវេមត្ត
## ពោធិរុក្ខវេមត្ត , បល្លង្កវេមត្ត

" សម្តែងដោយអគ្គបណ្ឌិត ប៊ុត សាវង្ស "

នាសាលាសតិប្បដ្ឋានបាត់ដំបង

ពិនិត្យ និងវាយកុំព្យូទ័រដោយ

ខ្ញុំព្រះករុណា អាត្មាភាព

**យង់ សុផាត** និងឧបាសក **ជឹម ជំនិត**

ថ្ងៃ ៨ រោច . ស្រាពណ៍ . កុរ ព.ស ២៥៥១

# ព្រះពុទ្ធ ២៨ ព្រះអង្គ (វេមត្តកថា)

**នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ( ព្រះសម្ពុទ្ធទាំងនោះគឺ )

១ **តណ្ហង្ករោ មហាវីរោ** ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ ។

២ **មេធង្ករោ មហាយសោ** ព្រះមេធង្ករ ព្រះអង្គមានយសធំ ។

៣ **សរណង្ករោ លោកហិតោ** ព្រះសរណង្ករ ព្រះអង្គធ្វើឱ្យជាប្រយោជន៍ដល់សត្វលោក ។



៤ **ទីបង្ករោ ជុតិន្ធរោ** ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញា ដ៏រុងរឿង ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ១០ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមលៀប ទ្រង់គង់នៅលើរតនបល្ល័ង្គ ដែលមានកម្ពស់ ៥៣ ហត្ថ ។

៥ **កោណ្ឌញ្ញោ ជនបាមោក្ខោ** ព្រះកោណ្ឌញ្ញៈ ព្រះអង្គជា ប្រធាននៃពពួកជន ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ១០ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដ

ទេ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមសាលកល្យាណី ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៥៧ ហត្ថ ។

**៦ មង្គលោ បុរិសាសភោ** ព្រះមង្គល ព្រះអង្គជាបុរសដ៏ប្រសើរ ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺន ឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មីម៉ឺនលោកធាតុ ទ្រង់មានព្រះយានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើមខ្ទឹង ទ្រង់គង់នៅលើរតន បល្ល័ង្កដែលមានកម្ពស់ ៥៧ ហត្ថ ។

**៧ សុមនោ សុមនោ ធីរោ** ព្រះសុមន ព្រះអង្គជាអ្នកប្រាជ្ញ មានព្រះហឫទ័យដ៏ល្អ ទ្រង់



មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់ មានព្រះកម្ពស់ ៩០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ១០ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមខ្ទឹង ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៦០ ហត្ថ ។

**៨ រេវតោ រតិវឌ្ឍនោ** ព្រះរេវត ព្រះអង្គញុំាងសេចក្តីត្រេកអរឱ្យចម្រើន ទ្រង់មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមខ្ទឹង ទ្រង់គង់នៅលើ រតនបល្ល័ង្កដែលមាន

កម្ពស់ ៥៣ ហត្ថ ។

៩ **សោភិតោ គុណសម្បន្នោ** ព្រះសោភិត ព្រះអង្គបរិបូណ៌ដោយព្រះគុណ ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៥៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាង ព្រះ ផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយាន ដោយប្រាសាទ ទ្រង់ត្រាស់ដឹងនៅក្រោមដើមខ្ទឹង ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៣៨ ហត្ថ ។

១០ **អនោមទស្សី ជនុត្តមោ** ព្រះអនោម_ទស្សី ព្រះអង្គឧត្តមជាងពពួកជន ទ្រង់មានព្រះ ជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះ កម្ពស់ ៥៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាង



ព្រះផ្នួស ១០ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដ ទេ ទ្រង់មានព្រះយាន ដោយអង្រឹង ទ្រង់ត្រាស់ដឹងនៅក្រោមដើមអង្គ្រង ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៣៨ ហត្ថ ។

១១ **បទុមោ លោកបជ្ជោតោ** ព្រះបទុម ព្រះអង្គញុំាងលោកឱ្យភ្លឺស្វាង ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៥៨ ហត្ថ ទ្រង់ មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មាន ព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោម ដើមម្រុំ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមាន កម្ពស់ ៣៨ ហត្ថ ។

១២ **នារទោ វរសារថី** ព្រះនារទ ព្រះអង្គ

ដូចជាសារថីដ៏ប្រសើរ ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយព្រះបាទ ទ្រង់ត្រាស់ដឹងនៅក្រោមដើមម្រុំ ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៥៧ ហត្ថ ។

**១៣ បទុមុត្តរោ សត្តសារោ** ព្រះបទុមុត្តរ ព្រះអង្គជាខ្លឹមសារនៃពួកសត្វ ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៥៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មី ១២ យោជន៍ ទ្រង់មានព្រះយានដោយប្រាសាទ ទ្រង់ត្រាស់ដឹងនៅ



ក្រោមដើមស្រល់ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៣៨ ហត្ថ ។

**១៤ សុមេធោ អប្បដិបុគ្គលោ** ព្រះសុមេធ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមស្តៅ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៥៧ ហត្ថ ។

**១៥ សុជាតោ សព្វលោកគ្គោ** ព្រះសុជាត ព្រះអង្គប្រសើរ លើសជាងសត្វលោកទាំងពួង ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះ

កម្ពស់ ៥០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៩ ខែ ទ្រង់មានព្រះរស្មី មិនប្រាកដទេ ទ្រង់មានព្រះយានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើមឫស្សី ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៣២ ហត្ថ ។

**១៦ បិយទស្សី នរាសភោ** ព្រះបិយទស្សី ព្រះអង្គប្រសើរ ជាងនរជន ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៦ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមថ្កាន់ ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៥៣ ហត្ថ ។



**១៧ អត្ថទស្សី ការុណិកោ** ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះ កម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើមចំប៉ា ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៥៣ ហត្ថ ។

**១៨ ធម្មទស្សី តមោនុទោ** ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មាន

ព្រះយានដោយប្រាសាទ ទ្រង់ត្រាស់ដឹងនៅក្រោមដើមទន្ទាប់ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៥៣ ហត្ថ ។

**១៩ សិទ្ធត្ថោ អសមោ លោកេ** ព្រះសិទ្ធត្ថព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៦០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ១០ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយអង្រឹង ទ្រង់ត្រាស់ដឹងនៅក្រោមដើមកណ្ណិការ ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៤០ ហត្ថ ។

**២០ តិស្សោ ច វទតំ វរោ** ព្រះតិស្សព្រះអង្គប្រសើរ ជាងអ្នកប្រាជ្ញខាងសំដីទាំងឡាយ



ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៦០ ហត្ថ ទ្រង់មានព្រះត្រកូលជា ក្សត្រ ទ្រង់សាងព្រះផ្នួស កន្លះខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើមធ្នង់ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៤០ ហត្ថ ។

**២១ ផុស្សោ ច វរទោ ពុទ្ធោ** ព្រះពុទ្ធទ្រង់ព្រះនាមផុស្ស ព្រះអង្គប្រទានទូវធម៌ដ៏ប្រសើរ ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៥៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមកន្ទួតព្រៃ ទ្រង់គង់នៅលើ

រតនបល្ល័ង្កដែលមានកម្ពស់ ៣៨ ហត្ថ ។

**២២ វិបស្សី ច អនូបមោ** ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ ទ្រង់មានព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ ទ្រង់ មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មី ៧ យោជន៍ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមបាដលិព្រឹក្ស ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៥៣ ហត្ថ ។

**២៣ សិខី សព្វហិតោ សត្ថា** ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឱ្យជាប្រយោជន៍ដល់សត្វទាំងពួង ទ្រង់មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៧០ ហត្ថ ទ្រង់មានព្រះត្រកូលជា



ក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះ រស្មី ៣ យោជន៍ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមស្វាយស ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៣២ ហត្ថ ។

**២៤ វេស្សភូ សុខទាយកោ** ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្ដីសុខ ទ្រង់មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ទ្រង់មានព្រះ កម្ពស់ ៦០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៦ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយអង្រឹង ទ្រង់ត្រាស់ដឹងនៅក្រោមដើមមហាសាលព្រឹក្ស ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៤០ ហត្ថ ។

**២៥ កកុសន្ធោ សត្ថវាហោ** ព្រះកកុសន្ធ

ព្រះអង្គនាំសត្វ ចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺ កិលេស ទ្រង់មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៤០ ហត្ថ ទ្រង់មានព្រះត្រកូលជាព្រាហ្មណ៍ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មី ១០ យោជន៍ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមច្រេស ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ២៦ ហត្ថ ។

**២៦ កោនាគមនោ រណញ្ជហោ** ព្រះកោនា-គមន ព្រះអង្គបំបាត់បង់នូវសត្រូវ គឺ កិលេស ទ្រង់មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៣០ ហត្ថ ទ្រង់មានព្រះត្រកូលជាព្រាហ្មណ៍ ទ្រង់សាងព្រះផ្នួស ៦ ខែ ទ្រង់មានព្រះរស្មីមិន



ប្រាកដទេ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមល្វា ទ្រង់គង់នៅលើរតន-បល្ល័ង្កដែលមានកម្ពស់ ២០ ហត្ថ ។

**២៧ កស្សបោ សិរិសម្បន្នោ** ព្រះកស្សប ព្រះអង្គបរិបូណ៌ ដោយសិរីទ្រង់មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ២០ ហត្ថ ទ្រង់មានព្រះត្រកូលជាព្រាហ្មណ៍ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយប្រាសាទ ទ្រង់ត្រាស់ដឹងនៅក្រោមដើមជ្រៃ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ១៥ ហត្ថ ។

**២៨ គោតមោ សក្យបុង្គវោ** ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ទ្រង់មាន

ព្រះជន្មាយុ ១០០ ឆ្នាំ ទ្រង់ មានព្រះកម្ពស់ ១៦ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៦ ឆ្នាំ ទ្រង់មានព្រះរស្មីមួយព្យាម ទ្រង់មានព្រះយានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើមអស្សត្ថព្រឹក្ស ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ១៤ ហត្ថ ។

**សូមអនុមោទនា បុណ្យ !!!**

បុណ្យនាំមកនូវសេចក្តីសុខចម្រើនកើនសម្បត្តិហូរហៀរ

**ចប់**



**បុជាធម្មទាន**

ដោយសប្បុរសជន ជាសិស្សគណ

គោរពជូន

លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស